**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍សកម្មភាពស្តីពីការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ថ្ងៃទី ១ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២៣

## ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅតំបន់ ទីក្រុងរណបជ្រោយចង្វារ(OCIC)

សកម្មភាពអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍ នៃពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកដោយមានការចូលរួមក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ូយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានការចូលរួមពីសំណាក់ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ព្រមទាំង និងអង្គកាដៃគូពាក់ព័ន្ធរួមមាន(KHANA, MHC, CWPD, AHF, FHI360(Epic) និង WNU) សរុបចំនួនប្រមាណ ៣៩រូប នៅមុំទីក្រុងរណបជ្រោយចង្វារ(OCIC) ដែលជាកន្លែងកីឡាករស្នាក់នៅ ដើម្បីផ្សព្វផ្សាយអប់រំសុខភាពស្តីពីជំងឺអេដស៍ និងចែកស្រោមអនាម័យជូនពួកគាត់។




សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

លើសពីនេះទៅទៀតថ្នាក់ដឹកនាំ និងក្រុមការងារបានមានមតិសំណេះសំណាល និងបានធ្វើការអប់រំផ្សព្វផ្សាយជុំវិញមេរោគអេដស៍ជំងឺអេដស៍ និងការបង្ការផ្សេងៗដោយថ្នាក់ដឹកនាំផ្ទាល់ និងក្រុមការងារទៅកាន់បងប្អូនកីឡាករទូកង





ប្រមាណជាង ៣០០ នាក់ ដែលកំពុងមានវត្តមាននៅស្តង់ជិតនោះដោយមានការសម្របសម្រួលពិសេសជាមួយប្រធានក្រុមរបស់កីឡាករទូកង ដោយ **លោកស្រីវេជ្ជបណ្ឌិត ទេព សំណាង** ជាអនុប្រធានក្រុមការងារដើម្បីសុំការអនុញ្ញាតអប់រំផ្សព្វផ្សាយការងារនេះក្នុងផងដែរក្រុមការងារក៏បានរំលេចឡើងនូវគោលបំណងរបស់ក្រុមការងារស្តីពីការបង្ការការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងណែនាំពី វិធីសាស្ត្រប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ និងប្រកបដោយសុវត្ថិភាព ជូនដល់បងប្អូនកីឡាករទូកង។ ជាកិច្ចបញ្ចប់ថ្ងៃទី១ ក្រុមការងារបានធ្វើការចែកជូននូវខិត្តប័ណ្ណអប់រំផ្សព្វផ្សាយនានារបស់ក្រុមការងារមជ្ឈមណ្ឌលជាតិ និងដៃគូពាក់ព័ន្ធរួមទាំង






អាវយឺត ស្រោម អនាម័យ ទឹករំអិល និងបាទទួលធ្វើតេស្តឈាមជូនបងប្អូនកីឡាករបានមួយចំនួនផងដែរ។

ជាផែនការគ្រោងទុកក្រុមការងារក្រុមការងារមជ្ឈមណ្ឌលជាតិ និងក្រុមអង្គការដៃគូពាក់ព័ន្ធបានត្រៀមទុកនូវកម្លាំងបុគ្គលិក សម្ភារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍ នៃពិធីបុណ្យអ៊ុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នូវស្រោមអនាម័យ ចំនួន ១០០,០០០ ស្រោម ទឹករំអិលចំនួន ៣០,០០០ កញ្ចប់ ខិត្តប័ណ្ណអំពីការការពារ និងធ្វើតេស្ត ចំនួន ២០,០០០ សន្លឹក ខិត្តប័ណ្ណ PrEP ចំនួន ២០,០០០ សន្លឹក អាវយឺត ចំនួន ១,០០០ អាវ និង ខិត្តប័ណ្ណអប់រំផ្សេងៗមួយចំនួនប្រមាណ ២០,០០០ ទៀត។

# សកម្មភាពចុះអប់រំផ្សព្វផ្សាយ និងសមិទ្ធផលរួមសម្រាប់ថ្ងៃទី ២៥ ខែ វិច្ឆិការ ឆ្នាំ ២០២៣

| ល.រ | សកម្មភាព | ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ផ្សេងៗ |
|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | ២,៥៤៦ នាក់ | |
| ២ | បានធ្វើតេស្តឈាម | ១៣ នាក់ | |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | ០ នាក់ | |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | ០ នាក់ | |
| ៥ | បានចែកស្រោមអនាម័យ | ១២,៩៨៤ ស្រោម | |
| ៦ | បានចែកទឹករំអិល | ៤,៥៥៨ កញ្ចប់ | |
| ៧ | បានចែកខិត្តប័ណ្ណ | ២,៦៨៧ សន្លឹក | |
| ៨ | បានចុះឈ្មោះសេវា PrEP | ០ នាក់ | |
| ៩ | អាវយឺតសម្រាប់អប់រំ | ២៥០ អាវ | |






ថ្ងៃសៅរ៍ ១៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០២៣

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | ធ្វើសេចក្តីរាយការណ៍ដោយ |
|---|---|---|
| សាស្ត្រាចារ្យ ជ.អ៊ឹក វិជ្ជា | វេជ្ជបណ្ឌិត ង៉ូវ បូរ៉ា | លោក ចំរើន បូរ៉ា |